# ក្រុមហ៊ុនច្បាប់ KIRSHENBAUM & GOSS ត្រូវបានចាត់តាំង

## ឲ្យតំណាងអ្នក

គេកំណត់ថា អ្នកមានសិទ្ធិទទួលបានមេធាវីការពារក្តីសាធារណៈ និងក្រុមហ៊ុនច្បាប់របស់យើងត្រូវបាន ចាត់តាំងឲ្យតំណាងអ្នក។ វាជាគោលដៅរបស់យើងក្នុងការផ្តល់នូវការតំណាងប្រកបដោ យគុណភាពខ្ពស់ និងជូនដំណឹងដល់អ្នក ទាក់ទងនឹងរឿងក្តីរបស់អ្នក។

## ទំនាក់ទំនងយើងខ្ញុំ

មេធាវីមកពីការិយាល័យរបស់យើងនឹងហៅទូរស័ព្ទ ឬផ្ញើអ៊ីម៉ែលទៅអ្នកនៅក្នុងរយៈពេលប៉ុន្មានថ្ងៃខាងមុខនេះ ដើម្បីបង្កើតទំនាក់ទំ នងដំបូង។ អ្នកក៏អាចទាក់ទងមកយើងតាមរយៈលេខទូរស័ព្ទ ឬអាសយដ្ឋានអ៊ីម៉ែលខាងលើ។ ការប្រាស្រ័យទាក់ទងគឺមាន សារៈសំខាន់ណាស់ចំពោះទំនាក់ទំនងដ៏ល្អរវាងមេធាវី និងកូនក្តី។

## ការណាត់ជួប

អ្នកក៏អាចកំណត់ពេលវេលាណាត់ជួបជាមួយមេធាវី។ ការណាត់ជួបដោយផ្ទាល់ជាទូទៅគឺនៅថ្ងៃចន្ទ និងថ្ងៃព្រហស្បតិ៍។ ប្រសិនបើ មានការលំបាកក្នុងការមកកាន់ការិយាល័យរបស់យើង ការណាត់ជួបតាមទូរស័ព្ទអាចត្រូវបានរៀបចំឡើង។ ប្រសិនបើអ្នក ចង់ធ្វើការណាត់ជួបយើងនៅការិយាល័យរបស់យើងហើយអ្នកត្រូវការអ្នកបកប្រែ យើងអាចផ្តល់អ្នកបកប្រែម្នាក់ជូនអ្នក។ អ្នកនឹងត្រូវអនុញ្ញាតឱ្យយើងដឹងថាអ្នកត្រូវការអ្នកបកប្រែម្នាក់មុននឹងការណាត់ជួបនៅការិយាល័យ។

## របាយការណ៍សមត្ថកិច្ច

បន្ទាប់ពីយើងត្រូវបានជូនដំណឹងអំពីរឿងក្តីរបស់អ្នក យើងនឹងរៀបចំឯកសារដែលគេហៅថា សេចក្តីជូនដំណឹងអំពីការបង្ហា ញខ្លួនដើម្បីផ្ញើទៅកាន់តុលាការ និងព្រះរាជអាជ្ញា។ ឯកសារនេះជូនដំណឹងដល់អយ្យការថា យើងតំណាងឱ្យអ្នកហើយ សុំឱ្យអយ្យការប្តូរឯកសារសំណុំរឿងរវាងគូក្តី។ នេះរួមមានរបាយការណ៍របស់សមត្ថកិច្ច ប៉ុន្តែអាចរួមបញ្ចូល ខ្សែអាត់វីដេអូ ឬខ្សែអាត់សំលេង។ វាអាចចំណាយពេលរហូតដល់ពីរសប្តាហ៍ដើម្បីទទួលបានសំណុំឯកសារទាំងនេះ ហើយក្នុងករណីភាគច្រើន វានឹងកាន់តែមានប្រសិទ្ធភាពក្នុងការជួបជាមួយនឹងអ្នកបន្ទាប់ពីយើងបានទទួលបានការប្តូរឯកសារសំណុំរឿងនេះរវាងគូក្តី។

## ការរៀបចំសំណុំរឿងក្តីរបស់អ្នក

នៅពេលដែលអ្នកជួបជាមួយមេធាវីរបស់អ្នក ត្រូវត្រៀមលក្ខណៈនិយាយរៀបរាប់អំពីរបស់រឿងហេតុ និងបញ្ជីឈ្មោះសាក្សីណាមួយ (រួមបញ្ចូលទាំងព័ត៌មានទំនាក់ទំនង) អ្នកជឿថាមានព័ត៌មានដែលពាក់ព័ន្ធទៅនឹងរឿងក្តីរបស់អ្នក។ ខណៈពេលដែលវាមិន ចាំបាច់ឲ្យអ្នកផ្តល់ជូនរឿងនេះជាលាយលក្ខណ៍អក្សរ វាមានសារប្រយោជន៍ណាស់ចំពោះយើងប្រសិនបើអ្នកធ្វើដូច្នេះ។

មេធាវីរបស់យើងទន្ទឹងរង់ចាំជួបអ្នក និងបម្រើតម្រូវការផ្នែកច្បាប់ជូនអ្នក។

KIRSHENBAUM & GOSS P.S.